**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គិសនីកម្ពុជា**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ: ..៣៥៩៦.. PC.អក

# សេចក្តីជូនដំណឹង
## ស្តីពី

ការផ្គត់ផ្គង់សម្ភារ និងឈ្នួលពលកម្ម សម្រាប់ការវិនិយោគខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម 22kV ចំនួន ០២ ទ្វារចេញ ចេញពីអនុស្ថានីយអគ្គិសនីទី ៨ (GS 8) ដើម្បីកាត់វិលែកបន្ទុក GS8-F3, F5 និង F17 ព្រមទាំងតម្លើង Overhead Ground Wiring System ជូន នាយកដ្ឋានអាជីវកម្មចែកចាយ

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា ៖ អគ្គិសនីកម្ពុជានឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការងារផ្គត់ផ្គង់សម្ភារ និងឈ្នួលពលកម្ម សម្រាប់ការវិនិយោគខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម 22kV ចំនួន ០២ ទ្វារចេញ ចេញពីអនុស្ថានីយអគ្គិសនីទី ៨ (GS 8) ដើម្បីកាត់វិលែកបន្ទុក GS8-F3, F5 និង F17 ព្រមទាំងតម្លើង Overhead Ground Wiring System ជូន នាយកដ្ឋានអាជីវកម្មចែកចាយ ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃមានដាក់លក់នៅអង្គភាពលទ្ធកម្មអគ្គិសនីកម្ពុជាដែលមានអាសយដ្ឋាន អាគារលេខ ២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ចាប់ពីថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០២០ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ៖ 023 67 66 007 / 092 652 357 និង Website : www.edc.com.kh ) ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹម ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០២០ វេលាម៉ោង ១៤:០០ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋាន ខាងលើ វេលាម៉ោង ១៥:៣០ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០២០ ។

ក្រុមហ៊ុន/សហគ្រាសដែលចូលរួមដាក់ឯកសារដេញថ្លៃ ស្នើសុំភ្ជាប់បន្ថែមមកជាមួយនូវឯកសារដេញថ្លៃ ដែលបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម និងភ្ជាប់មកជាមួយនូវ Soft Copy ដែលជាឯកសារ Scan របស់ឯកសារដេញថ្លៃនេះ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃអង្គារ ១កើត ខែស្រាពណ៍ ឆ្នាំ ជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ២០២០
**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ហេង_នួច**

ចម្លងជូន ៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ